# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៤៣៦ សហវ.វិស

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១០

### ជម្រាបជូន
### ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
### នៃអគ្គនាយកដ្ឋានរតនាគារជាតិ

**កម្មវត្ថុ** : ករណីសំណើសុំបុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្មក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារជួសជុលទំនប់អាងទឹកអូរចាប ស្ថិតក្នុងឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង ។

**យោង** : - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ២២៤ សហវ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ ៩៦៤ ធទឧ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១០ របស់ក្រសួងធនធានទឹកនិងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមប្រតិភូជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឲ្យក្រសួងធនធានទឹកនិងឧតុនិយម បុរេប្រទានថវិកាជំពូក២១ «គម្រោងវិនិយោគផ្ទាល់» ចំនួន ៩៣៧.០០០.០០០រៀល (ប្រាំបួនរយសាមសិបប្រាំពីរលានរៀលគត់) ជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ចាប់ផ្តើមអនុវត្តការងារជួសជុលទំនប់អាងទឹកអូរចាប ស្ថិតក្នុងឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង ។

ខ្ទង់ប្រាក់បុរេប្រទាននេះ នឹងត្រូវទូទាត់ឥណទានថវិការបស់ក្រសួងធនធានទឹកនិងឧតុនិយម ដោយអាណត្តិបើកប្រាក់ឲ្យបានទាន់ពេលវេលា ។

សូមឯកឧត្តមប្រតិភូមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន</u>**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ»
- ឯកសារ-កាលប្បវត្តិ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom, khan Daun Penh, Phnom Penh. CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com